# ព្រះគម្ពីរសំរាប់កុមារ
សូមបង្ហាញជូន

# បុណ្យព្រះយេស៊ូរស់ឡើងវិញពីសេចក្តីស្លាប់ជាលើកដំបូង




និពន្ធដោយៈ Edward Hughes
ធ្វើការពន្យល់ដោយៈ Janie Forest
Alastair Paterson

បកប្រែដោយៈ www.christian-translation.com
កែសម្រួលដោយៈ Lyn Doerksen



រឿងទី ៥៤ នៃ ៦០

**www.M1914.org**

***Bible for Children,*** *PO Box 3, Winnipeg, MB R3C 2G1 Canada*



អាជ្ញាប័ណ្ណៈ លោកអ្នកមានសិទ្ធិក្នុងការថតចម្លង ឬបោះពុម្ពរឿងនេះបាន
តែលោកអ្នកមិនអាចយកវាទៅលក់បានទេ។


ភាសាខ្មែរ

Khmer

ស្ត្រីម្នាក់បានឈរនៅក្បែរភ្នំដ៏អ៊ូរអរ ភ្នែកពោរពេញដោយសេចក្តីទុក្ខព្រួយ សំលឹងមើលទៅទិដ្ឋភាពដ៏គួរអោយរន្ធត់។ កូនរបស់គាត់កំពុងជិតបាត់បង់ជីវិត។ ម៉ារីជាម្តាយបានឈរនៅជិតកន្លែងដែលព្រះយេស៊ូត្រូវបានគេដំដែកគោលភ្ជាប់ទៅនឹងឈើឆ្កាង។



1



តើរឿងទាំងនេះកើតឡើងបានយ៉ាងដូចម្តេចទៅ? ហេតុដូចម្តេចបានជាព្រះយេស៊ូបញ្ចប់ជីវិតដ៏ស្រស់ស្អាតរបស់ទ្រង់ក្នុងសភាពដ៏អាក្រក់បែបនេះ? ហេតុអ្វីបានជាព្រះជាម្ចាស់អនុញ្ញាតអោយគេដំដែកគោលព្យួរព្រះបុត្រារបស់ទ្រង់ទៅនឹងឈើឆ្កាងដើម្បីបញ្ចប់ជីវិតនៅទីនោះ? តើព្រះយេស៊ូភាន់ច្រឡំពីអត្តសញ្ញាណរបស់ទ្រង់ឬ? តើព្រះជាម្ចាស់បានបរាជ័យហើយឬ?

2



ទេ! ព្រះជាម្ចាស់មិនបាន
បរាជ័យទេ។ ព្រះយេស៊ូក៏
មិនបានភាន់ច្រឡំអ្វីដែរ។
ព្រះយេស៊ូបានដឹងជានិច្ចថា
ទ្រង់នឹងត្រូវសុគត
ដោយសារមនុស្សអាក្រក់។
សូម្បីតែពេលដែលព្រះយេស៊ូ
នៅជាទារកនៅឡើយ បុរស
ចំណាស់ម្នាក់ឈ្មោះ សាយ
មិន ក៏បានប្រាប់ម៉ារីថា ក្តី
ទុក្ខព្រួយនឹងកើតមាន
ឡើងនៅពេលខាងមុខ។

3



ពីរបីថ្ងៃ
មុនពេលដែលព្រះ
យេស៊ូត្រូវបានគេធ្វើគុត
ស្ត្រីម្នាក់បានមក ហើយ
ចាក់ប្រេងទឹកអប់លើព្រះ
បាតរបស់ទ្រង់។ ពួកសិស្ស
បានរអ៊ូរទាំថា “ស្ត្រីម្នាក់នេះ
កំពុងខ្ជះខ្ជាយប្រាក់របស់
គាត់ហើយ”។ ព្រះយេស៊ូបានមានព្រះ
បន្ទូលថា “ស្ត្រីម្នាក់នេះធ្វើបាន
ល្អណាស់, គាត់ធ្វើនេះសំរាប់ជាកិច្ចបញ្ចុះ
សពរបស់យើង។” នេះជាព្រះបន្ទូលដ៏ចម្លែកណាស់!

4

ក្រោយពីនោះមក យូដាស
ដែលជាកូនសិស្សម្នាក់ក្នុង
ចំណោមសិស្សទាំង១២នាក់
របស់ព្រះយេស៊ូ បានយល់ព្រម
ជាមួយពួកប្រធានសង្ឃក្បត់
នឹងព្រះយេស៊ូ ដោយទទួល
បានដុំប្រាក់ ចំនួន៣០ដុំ។



5



នៅពិធីបុណ្យរំលងរបស់សាសន៍ជូហ្វ
ព្រះយេស៊ូបានសោយភោជនាហារចុង
ក្រោយរបស់ទ្រង់ជាមួយពួកសិស្សរបស់
ទ្រង់។ ទ្រង់បានប្រាប់ពួកគេពីរឿងអ
ស្ចារ្យរបស់ព្រះជាម្ចាស់ និងការសន្យា
របស់ទ្រង់ចំពោះអ្នកដែលស្រលាញ់ទ្រង់។
បន្ទាប់មក ព្រះយេស៊ូបានប្រទាននំប៉័ង
និងទឹកមួយពែងចែករំលែកដល់ពួក
គេ។ ទាំងនេះជាការរំលឹកដល់
ពួកគេថាព្រះយេស៊ូ
ប្រទានព្រះកាយ
និងព្រះលោហិត
របស់ទ្រង់ដើម្បីទទួល
បានការអភ័យទោស
ចំពោះអំពើបាប។

6

ក្រោយមក ព្រះយេស៊ូបានប្រាប់មិត្តរបស់ទ្រង់ថា មាន
មនុស្សក្បត់ទ្រង់ ហើយពួកគេនឹងរត់ចោលទ្រង់។ ភីតធើ
បានបញ្ជាក់ហើយបញ្ជាក់ទៀតថា “ទោលបង្គំមិនរត់ចោល
ទ្រង់ទេ”។ ព្រះយេស៊ូបានមានព្រះបន្ទូលថា“មុនពេល
មាន់រងាវ អ្នកនឹងបដិសេធនឹងយើងចំនួន៣ដង”។



7



ក្រោយមកនៅយប់នឹង
ព្រះយេស៊ូបានយាងទៅ
បួងសួងនៅក្នុងសួន
ហ្គិតសេមេន។ ពួកសិស្ស
ដែលនៅជាមួយទ្រង់បាន
ដេកលក់អស់។ ព្រះយេស៊ូ
បានបួងសួង “ឱ ព្រះវរ
បិតានៃទូលបង្គំអើយ...
សូមអោយពែងនេះឆ្លង
កាត់ពីទូលបង្គំទៅ។ ប៉ុន្តែ
សូមកុំអោយកើតឡើង
តាមចិត្តរបស់ទូលបង្គំ
ឡើយ សូមកើតឡើង
តាមព្រះហឫទ័យរបស់
ទ្រង់វិញ។”

8


រំពេចនោះ ហ្វូងមនុស្សកកកុញបានចូលមកក្នុងសួន, ដឹកនាំដោយពួកយូដាស។ ព្រះយេស៊ូមិនបានរឹងទទឹងឡើយ ប៉ុន្តែ ភីតធើវិញបានកាត់ត្រចៀករបស់បុរសម្នាក់ចោល។ ព្រះយេស៊ូបានប៉ះត្រចៀកបុរសម្នាក់នោះដោយស្ងៀមស្ងាត់ ហើយបានព្យាបាលគាត់។ ព្រះយេស៊ូបានដឹងថាការចាប់ខ្លួនរបស់ទ្រង់គឺជាផ្នែកមួយនៃបំណងរបស់ព្រះជាម្ចាស់។
9

មនុស្សទាំងនោះបាននាំព្រះយេស៊ូទៅផ្ទះរបស់សម្តេចសង្ឃ។ នៅពេលនោះ មេដឹកនាំជូហ្វបាននិយាយថា ព្រះយេស៊ូគួរតែសុគត។ នៅជិតនោះ ភីតធើបានឈរជិតភ្លើងរបស់អ្នកបម្រើ ហើយសំលឹងមើល។
10

មនុស្សបីនាក់បានសំលឹងមើលភីតធើដោយមិនដាក់ភ្នែក ហើយបាននិយាយថា “អ្នកអែងនៅជាមួយនឹងព្រះយេស៊ូ!” ភីតធើបានប្រកែកចំនួន ៣ដង ដូចដែលព្រះយេស៊ូបានមានបន្ទូល។ ភីតធើបានជេរដាក់បណ្តាសា ហើយបានទាំងស្បថស្បែរទៀតផង ថាមិនបាននៅជាមួយព្រះយេស៊ូ។
11

ក្ពុក-កាក-ក្ពុក-ក្ពុក
ក្រោយមក មាន់បានរងាវ។ ដូចជាសំលេងព្រះជាម្ចាស់ទៅកាន់ភីតធើ។ ភីតធើបានចងចាំពាក្យរបស់ព្រះយេស៊ូ ហើយបានទ្រហរយំយ៉ាងខ្លាំង។
12

យូដាសក៏មានអារម្មណ៍សោកស្តាយដែរ។ គេបានដឹងថាព្រះយេស៊ូមិនបានប្រព្រឹត្តអំពើបាប ឬឧក្រិឌកម្មណាមួយឡើយ។ យូដាសបានយកដុំប្រាក់៣០ដុំទៅអោយពួកសង្ឃវិញតែពួកគេមិនយក។ យូដាសបានបោះដុំលុយទាំងនោះចោល, ដើរចេញទៅ-ហើយចងកសំលាប់ខ្លួន។
13

ពួកសង្ឃបាននាំព្រះយេស៊ូទៅជួប ពីឡាត់, ដែលជាអភិបាលរបស់ពួកសាសន៍រ៉ូម។ ពីឡាត់បាននិយាយថា “បុរសម្នាក់នេះមិនមានកំហុសអ្វីទេ។” ប៉ុន្តែបណ្តាជនចេះតែបន្តស្រែកថា “ឆ្កាងគេទៅ! ឆ្កាងគេទៅ!”
14


ទីបំផុត ពីឡាត់បានសុខចិត្តធ្វើស្របតាម
អ្វីដែលបណ្ដាជនចង់បាន ហើយបានដាក់
ទោសព្រះយេស៊ូអោយស្លាប់លើឈើឆ្កាង។
ពួកទាហានបានដាល់ព្រះយេស៊ូ, ស្ដោះទឹក
មាត់ដាក់ព្រះភក្ត្រ័ព្រះអង្គ ហើយវាយព្រះ
កាយទ្រង់។ ពួកគេបានធ្វើម្កុដដ៏សាហាវ
មួយចេញពីមែកបន្លាដែលមុតស្រួចវែង
ហើយបានសង្កត់វាលើព្រះសិរសាររបស់ទ្រ
ង់។ បន្ទាប់មក ពួកគេបានដំដែកគោល
ទ្រង់ទៅនឹងឈើឆ្កាងរហូត
ដល់សោយទីវង្គត់។
15
ព្រះយេស៊ូទ្រង់បានដឹងជានិច្ចហើយថាទ្រង់នឹងសុគតរបៀប
នេះ។ ទ្រង់ក៏បានដឹងផងដែរថា ការសុគតរបស់ទ្រង់នឹងនាំ
មកនូវការអភ័យទោសសំរាប់ជនអ្នកប្រព្រឹត្តអំពើបាបដែល
បានដាក់ជំនឿរបស់ពួកគេលើទ្រង់។
ឧក្រិឌជន២នាក់ត្រូវបានឆ្កាង
នៅជិតព្រះយេស៊ូ។ ម្នាក់ដែល
មានជំនឿលើព្រះយេស៊ូ គាត់
បានឡើងទៅលើឋានសួគ៍។
ហើយម្នាក់ទៀតដែលមិនជឿ
លើព្រះយេស៊ូ មិនបានឡើង
ទៅឋានសួគ៍ទេ។
16
បន្ទាប់ពីទទួលការរងទុក្ខជាច្រើន
ម៉ោងហើយនោះ, ព្រះយេស៊ូបាន
មានបន្ទូលថា “វាចប់ហើយ”
ហើយទ្រង់ក៏សុគតទៅ។
ការងាររបស់ទ្រង់បាន
ចប់សព្វគ្រប់ហើយ។
មិត្តទ្រង់បានបញ្ចុះ
សពទ្រង់ក្នុងផ្នូរ
ឯកជនមួយ។
17
បន្ទាប់មកពួក
ទាហានរ៉ូមបានឡោម
ព័ទ្ធ ហើយបានយាម
ផ្នូរនោះ។ ពេលនេះ
គ្មាននរណាម្នាក់អាច
ចេញចូលបានទេ។
18
ប្រសិនបើនេះជាទីបញ្ចប់
របស់សាច់រឿង មិនដឹង
ជាកំសត់ប៉ុន្នាទេ។ ប៉ុន្តែ
ព្រះជាម្ចាស់បានធ្វើអ្វី
ម៉្យាងដែលអស្ចារ្យ។ ព្រះ
យេស៊ូមិនបានបន្តជា
សាកសពនោះទេ!
19
នាពេលព្រឹកព្រលឹមនៅថ្ងៃទីមួយក្នុង
សប្តាហ៍នោះ, ពួកសិស្សរបស់ព្រះ
យេស៊ូមួយចំនួនបានឃើញ
ថាដុំថ្មបានរមៀលចេញពី
ផ្នូរ។ នៅពេលដែលពួក
គេសំលឹងមើលនៅ
ខាងក្នុង គេមិន
ឃើញព្រះ
យេស៊ូនៅទីនោះ
ទៀតឡើយ។
20



ព្រះយេស៊ូបានលេចឡើងចំពោះមុខស្ត្រីម្នាក់ ដែលគាត់បាននៅបន្ទយំនៅជិតផ្នូររបស់ទ្រង់។ បន្ទាប់ពីបានឃើញព្រះយេស៊ូ គាត់បានប្រញាប់ប្រញាលត្រលប់ទៅប្រាប់ពួកសិស្សដទៃទៀតយ៉ាងសប្បាយរីករាយ។ “ព្រះយេស៊ូនៅមានជីវិត!

ព្រះយេស៊ូបានរស់ឡើងវិញពីសេចក្តីស្លាប់!”

21



មិនយូរប៉ុន្មាន ព្រះយេស៊ូបានទៅជួបពួកសិស្សរបស់ទ្រង់ ហើយបានបង្ហាញពួកគេនូវស្នាមដែកគោលនៅនឹងដៃទ្រង់។ វាជាការពិត ព្រះយេស៊ូមានជីវិតម្តងទៀត! ទ្រង់លើកទោសអោយភីតធើដែលបានបដិសេធថាមិនបាននៅជាមួយទ្រង់ ហើយទ្រង់បានប្រាប់ពួកសិស្សទ្រង់អោយប្រាប់ទៅគ្រប់គ្នាអំពីទ្រង់។ បន្ទាប់មកទ្រង់បានយាងត្រលប់ទៅឋានសួគ៌វិញដែលជាទីកន្លែងដែលទ្រង់បានយាងមកនោះ។

22

បុណ្យព្រះយេស៊ូវរស់ឡើងវិញពីសេចក្តីស្លាប់ជាលើកដំបូង

រឿងមួយពីព្រះបន្ទូលរបស់ព្រះជាម្ចាស់, ព្រះគម្ពីរ,

អាចរកឃើញនៅក្នុង

ម៉ាថាយ ២៦-២៨, លូកា ២២-២៤,
យ៉ូហាន ១៣-២១

“ការបើកសម្តែងនូវព្រះបន្ទូលទ្រង់ផ្តល់នូវពន្លឺ។”
ទំនុកតម្កើង ១១៩៖ ១៣០

ព្រះអង្គជ្រាបថាយើងបានប្រព្រឹត្តអំពើអាក្រក់ ដែលទ្រង់ហៅការទាំងនោះថាអំពើបាប។ ទោសនៃអំពើបាបគឺសេចក្តីស្លាប់។

ព្រះទ្រង់ស្រឡាញ់យើងខ្លាំងណាស់ ដល់ម្ល៉េះហើយបានជាទ្រង់បានចាត់ព្រះយេស៊ូដែលជាព្រះរាជបុត្រាតែមួយរបស់ព្រះអង្គអោយមកសុគតនៅលើឈើឆ្កាង ហើយបង់ថ្លៃនៃទោសនោះជំនួសយើង។ ព្រះយេស៊ូបានរស់ពីសុគតឡើងវិញ ហើយបានយាងត្រលប់ទៅស្ថានសួគ៌! ពេលនេះព្រះអង្គអាចអភ័យទោសរាល់អំពើបាបរបស់យើងបានហើយ។

ប្រសិនបើអ្នកចង់បែរចេញពីអំពើបាបរបស់អ្នក អ្នកត្រូវទូលទៅកាន់ព្រះអង្គថា៖ ព្រះអង្គអើយ ទូលបង្គំជឿហើយថា ព្រះយេស៊ូបានសុគតជំនួសខ្ញុំ ហើយទ្រង់បានរស់ឡើងវិញពីសេចក្តីស្លាប់។ សូមទ្រង់ចូលមកក្នុងជីវិតរបស់ទូលបង្គំ ហើយអភ័យទោសចំពោះអំពើបាបរបស់ទូលបង្គំ ដើម្បីអោយទូលបង្គំអាចមានជីវិតថ្មីនាពេលឥឡូវនេះបាន ហើយបន្ទាប់មកនឹងបានទៅនៅជាមួយទ្រង់ជារៀងរហូត។ សូមជួយទូលបង្គំអោយរស់នៅសំរាប់ទ្រង់ ដូចជាបុត្ររបស់ទ្រង់។
អាមែន។ យូហាន ៣៖១៦

សូមអានព្រះគម្ពីរ ហើយអធិដ្ឋានទូលទៅកាន់ព្រះជារៀងរាល់ថ្ងៃ!